**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៨២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សិទ្ធិអំណាច តួនាទី ភារកិច្ច និងនីតិវិធីផ្សេងៗក្នុងការអនុវត្ត របស់មន្ត្រីអធិការកិច្ចប្រេងកាត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញព្រះរាជក្រមលេខ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីសិទ្ធិអំណាច តួនាទី ភារកិច្ច និងនីតិវិធីផ្សេងៗក្នុងការអនុវត្តរបស់មន្ត្រីអធិការកិច្ចប្រេងកាត ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការធ្វើអធិការកិច្ចលើរាល់សកម្មភាពក្នុងវិស័យប្រេងកាតស្របតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវកំណត់និយមន័យដូចខាងក្រោម៖

១- **មន្ត្រីអធិការកិច្ចប្រេងកាត** សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដើម្បីតាមដានស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន និងទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

២- **សិទ្ធិក្នុងវិស័យប្រេងកាត** សំដៅដល់សិទ្ធិដែលរូបវន្តបុគ្គលឬនីតិបុគ្គលទទួលបានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីធ្វើសកម្មភាពផ្នែកអាប់ស្ទ្រីមនិងផ្នែកដោនស្ទ្រីម និងសកម្មភាពសំខាន់ៗដែលពាក់ព័ន្ធ។

## ជំពូកទី២

## សិទ្ធិអំណាច តួនាទី និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចប្រេងកាត

**មាត្រា៤ .-**

មន្ត្រីអធិការកិច្ចប្រេងកាត មានសិទ្ធិអំណាចដូចខាងក្រោម៖

- ត្រួតពិនិត្យបទល្មើសនានាក្នុងវិស័យប្រេងកាត រួមមានធ្វើការឆែកឆេរ ចាប់យកវត្ថុតាង បិទស្លាក

បោះត្រាលើវត្ថុតាង និងបំពេញមុខងារផ្សេងទៀត ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ

- ធ្វើអធិការកិច្ចតាមកាលកំណត់ឬមិនតាមកាលកំណត់ ដោយមានការជូនដំណឹងជាមុនឬដោយពុំមានការជូនដំណឹងជាមុន ដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសកម្មភាពក្នុងវិស័យប្រេងកាត
- ផ្អាកសកម្មភាពឬឃាត់ទុកជាបណ្តោះអាសន្នមធ្យោបាយបម្រើឱ្យសកម្មភាពក្នុងវិស័យប្រេងកាត ដែលអាចបង្កគ្រោះថ្នាក់ ឬហានិភ័យធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម ឬដែលល្មើសនឹងបទប្បញ្ញត្តិបច្ចេកទេស ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ដោយផ្អែកតាមនីតិវិធីច្បាប់ជាធរមាន
- ចាត់វិធានការនានា ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសកម្មភាពក្នុងវិស័យប្រេងកាត ល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន និង
- ស្នើសុំជំនួយសហការពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចូលរួមបង្ក្រាបបទល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត។

**មាត្រា៥ .-**

មន្ត្រីអធិការកិច្ចប្រេងកាតមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ពង្រឹងអនុលោមភាពនិងជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន
- តាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ព្រមទាំងត្រួតពិនិត្យបទល្មើសឬសកម្មភាពដែលអាចបង្កបទល្មើសក្នុងវិស័យប្រេងកាត
- ណែនាំឱ្យកែតម្រូវនូវកំហុសដែលអាចបង្កគ្រោះថ្នាក់ឬហានិភ័យធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម
- ធ្វើរបាយការណ៍ និងលើកសំណើសុំការពិនិត្យនិងសម្រេចតាមការចាំបាច់ពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន
- ចូលរួមអប់រំនិងផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធផ្សេងទៀតជាធរមាន និង
- បំពេញភារកិច្ចផ្សេងទៀតស្របតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៦ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល អាចចាត់តាំងក្រុមការងារចុះត្រួតពិនិត្យនិងអធិការកិច្ចលើរាល់សកម្មភាពក្នុងវិស័យប្រេងកាត ដើម្បីដឹកនាំនិងសម្របសម្រួលការងារអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចប្រេងកាត និងមន្ត្រីសមត្ថកិច្ចជំនាញក្នុងការគ្រប់គ្រង និងត្រួតពិនិត្យរាល់សកម្មភាពក្នុងវិស័យប្រេងកាត។

**មាត្រា៧ .-**

មន្ត្រីអធិការកិច្ចប្រេងកាត ត្រូវអនុវត្តសិទ្ធិអំណាច តួនាទី និងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន ដោយមនសិការវិជ្ជាជីវៈ និងត្រូវមានការទទួលខុសត្រូវលើសកម្មភាពអធិការកិច្ចរបស់ខ្លួន។

## ជំពូកទី៣
## នីតិវិធីនៃការធ្វើអធិការកិច្ចប្រេងកាត

**មាត្រា៨ .-**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចប្រេងកាតត្រូវស្លៀកពាក់ឯកសណ្ឋាននិង/ឬសញ្ញាសម្គាល់ ព្រមទាំងមានលិខិតអនុញ្ញាតឱ្យបំពេញបេសកកម្ម។

**មាត្រា៩ .-**

ការចាត់វិធានការរបស់មន្ត្រីអធិការកិច្ចប្រេងកាតចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តកំហុសពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

ដោយផ្អែកតាមស្ថានភាពជាក់ស្តែងនៃបទល្មើស មន្ត្រីអធិការកិច្ចប្រេងកាតត្រូវអនុវត្តវិធានការណាមួយឬច្រើនក្នុងចំណោមវិធានការដូចខាងក្រោម៖

- ចេញលិខិតឱ្យកែតម្រូវឬលិខិតព្រមាន
- ហាមឃាត់ជាបណ្តោះអាសន្នចំពោះសកម្មភាពក្នុងវិស័យប្រេងកាតនិងសកម្មភាពពាក់ព័ន្ធ
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ពិនិត្យនិងសម្រេចលើការព្យួរឬដកហូតសិទ្ធិក្នុងវិស័យប្រេងកាត
- ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង
- អនុវត្តការជាកពិន័យ និង/ឬកសាងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការ។

**មាត្រា១០ .-**

មន្ត្រីអធិការកិច្ចប្រេងកាតអាចស្នើសុំជំនួយពីអង្គភាពប្រដាប់អាវុធ ឬរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និង/ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចូលរួមពិនិត្យនិងបង្ក្រាបបទល្មើសក្នុងវិស័យប្រេងកាតដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន។

អង្គភាពប្រដាប់អាវុធ ឬរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និង/ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវសហការសម្របសម្រួល និងចាត់វិធានការនានាតាមការស្នើសុំពាក់ព័ន្ធនឹងដំណើរការនៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចប្រេងកាត។

**មាត្រា១១ .-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចប្រេងកាត អាចប្តឹងតវ៉ាតាមនីតិវិធីដូចមានបញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតជាធរមាន។

**មាត្រា១២ .-**

បែបបទនិងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចលើរាល់សកម្មភាពក្នុងវិស័យប្រេងកាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៤

## ទណ្ឌកម្ម

**មាត្រា១៣ .-**

មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនស្របតាមអនុក្រឹត្យនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ក្នុងករណីប្រព្រឹត្តកំហុស មន្ត្រីអធិការកិច្ចប្រេងកាតត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនទាន់គិតពីទណ្ឌកម្មព្រហ្មទណ្ឌ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ជនណាក្លែងបន្លំជាមន្ត្រីអធិការកិច្ចប្រេងកាត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា១៤ .-**

បុគ្គលណាដែលធ្វើសកម្មភាពរាំងឬបង្កឱ្យមានការរាំងស្ទះដល់ដំណើរការនៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចប្រេងកាត ត្រូវផ្តន្ទាទោសនិងពិន័យជាប្រាក់ស្របតាមមាត្រា៦៧នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ ៣៨ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ